ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ............✓..............

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ភាពជោគជ័យនៃការប្រើប្រាស់មូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន

ក្រសួងរ៉ែនិងថាមពល មានកិត្តិយសសូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា រ៉ែសំណង់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់វត្ថុធាតុដើម មានថ្មសំណង់ ក្រួស ខ្សាច់ ឡាតេរីត សម្រាប់បម្រើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ អគ្គិសនី កំពង់ផែ អាកាសយានដ្ឋាន ស្ពាន វារីអគ្គិសនី ទំនប់ធារាសាស្ត្រ និងសំណង់នានាដទៃទៀតទូទាំងប្រទេស។ ផលិតផលស៊ីម៉ងត៍ ដែលកម្ពុជាធ្លាប់តែធ្វើការនាំចូលទាំងស្រុងកាលពីអំឡុងទសវត្សរ៍ឆ្នាំ២០០០ ឥឡូវនេះត្រូវបានជំនួសវិញ ដោយផលិតផលស៊ីម៉ងត៍ក្នុងស្រុកដែលឆ្លើយតបបានតាមតម្រូវការសាងសង់នានា និងឈានទៅរកការនាំចេញទៅក្រៅប្រទេសទៀតផង។ ចំណែកឯឧស្សាហកម្មអាជីវកម្មរ៉ែមាសកម្រិតអន្តរជាតិបានលេចចេញជារូបរាងកាលពីឆ្នាំ២០២១ ស្របតាមគោលនយោបាយជាតិស្តីពីធនធានរ៉ែ។

ការអភិវឌ្ឍនធនធានរ៉ែខាងលើនេះមុនឆ្នាំ១៩៩៨ កម្ពុជាមិនអាចធ្វើការអភិវឌ្ឍបានទេ ដោយសាររបបវាលពិឃាត និងសង្គ្រាមស៊ីវិល។ លុះក្រោយឆ្នាំ១៩៩៨ បន្ទាប់ពីយើងទទួលបានសុខសន្តិភាពពេញលេញក្រោមគោលនយោបាយឈ្នះ-ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានធ្វើឱ្យខឿនសេដ្ឋកិច្ចនិងសង្គមរបស់ប្រទេសកម្ពុជាមានការរីកចម្រើនគ្រប់វិស័យ ក្នុងនោះវិស័យរ៉ែបានចាប់ផ្តើមមានសកម្មភាពអភិវឌ្ឍន៍គួរជាទីមោទនៈ ទោះបីជាវិស័យរ៉ែនៅកម្ពុជានៅក្មេងខ្ចី ក៏កម្ពុជាបានខិតខំប្រឹងប្រែងអភិវឌ្ឍវិស័យនេះ តាមរយៈការទាក់ទាញវិនិយោគិន និងបានបង្កើតប្រភពចំណូលថ្មីបន្ថែមគួរឱ្យកត់សម្គាល់។

ទន្ទឹមនឹងភាពរីកចម្រើនយ៉ាងឆាប់រហ័សក្នុងវិស័យរ៉ែ កាលពីឆ្នាំ២០១៥ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក៏បានផ្តួចផ្តើមឱ្យក្រសួងរ៉ែនិងថាមពលយកចិត្តទុកដាក់ និងគិតគូរពីផលប្រយោជន៍ជូនប្រជាពលរដ្ឋដែលរស់នៅជាប់ពាក់ព័ន្ធនឹងតំបន់វិនិយោគធនធានរ៉ែដោយផ្ទាល់បន្ថែមទៀត តាមរយៈការចូលរួមអភិវឌ្ឍន៍ក្នុងសហគមន៍មូលដ្ឋានបន្ថែមពីលើគម្រោងអភិវឌ្ឍថ្នាក់ជាតិ។ ក្នុងឆ្នាំ២០១៥ ក្រសួងរ៉ែនិងថាមពល ដោយមាន **ឯកឧត្តម ស៊ុយ សែម** ជារដ្ឋមន្ត្រី បានបង្កើតមូលនិធិឈ្មោះថា «មូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន» និងបានប្រើប្រាស់មូលនិធិនេះប្រកបដោយតម្លាភាពសម្រាប់គោលដៅចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋានដែលមានគម្រោងវិនិយោគធនធានរ៉ែស្ថិតនៅ។

ក្រសួងរ៉ែ និងថាមពល



លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

ក្រោមការដឹកនាំបន្តដ៏ឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បាននាំមកនូវស្ថិរភាពនយោបាយ សន្តិសុខរឹងមាំ ប្រជាពលរដ្ឋមានកម្រិតជីវភាពកាន់តែល្អប្រសើរឡើង និងបានណែនាំឱ្យក្រសួងរ៉ែនិងថាមពលត្រូវបន្តប្រើប្រាស់ **មូលនិធិរ៉ែ** ឱ្យកាន់តែមានប្រសិទ្ធភាព និងតម្លាភាព។ គិតត្រឹមខែកក្កដា ឆ្នាំ២០២៥ ក្រសួងរ៉ែនិងថាមពល បានប្រើប្រាស់ **មូលនិធិរ៉ែ** ចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋានទូទាំងប្រទេសបានចំនួន **៩៩ គម្រោង** ដែលចំណាយថវិកាអស់ប្រមាណ **៦,៥ លានដុល្លារអាមេរិក** និងមាន **៣១ គម្រោង** ទៀតគ្រោងនឹងអនុវត្តក្នុងឆមាសទី២ ឆ្នាំ២០២៥ នេះ ដែលគិតជាថវិកាប្រមាណជាង **២,៦ លានដុល្លារអាមេរិក** បន្ថែមទៀត។

ក្រសួងរ៉ែនិងថាមពលប្តេជ្ញាបន្តគ្រប់គ្រងនិងប្រើប្រាស់ **មូលនិធិរ៉ែ** សំដៅដល់ការចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋានដែលមានគម្រោងវិនិយោគធនធានរ៉ែស្ថិតនៅ ឱ្យមានប្រសិទ្ធភាព និងតម្លាភាព។

អាស្រ័យហេតុនេះ សូមសាធារណជន អ្នកសារព័ត៌មានជាតិ និងអន្តរជាតិជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០២៥



លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤

**#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh**